ANNA & ASSOCIATES
Law Office

# ព័ត៌មានថ្មីៗ – ការបើកបរបណ្ដាលឱ្យអ្នកដទៃស្លាប់ដោយអចេតនា

## ការទទួលខុសត្រូវចំពោះការបើកបរបណ្តាលឱ្យអ្នកដទៃស្លាប់ដោយអចេតនា

*ថ្ងៃទី២៣ ខែមេសា ឆ្នាំ២០២៦ – រាជធានីភ្នំពេញ – ព្រះរាជាណាចក្រកម្ពុជា*

នៅក្នុងករណីដែលមាននូវហេតុការណ៍មួយ ដែលបុគ្គលម្នាក់បើកបរដោយខ្វះការប្រុងប្រយ័ត្ន ក្នុងល្បឿនលឿន ហើយបណ្តាលឱ្យអ្នកដទៃបាត់បង់ជីវិតជាច្រើននាក់ដោយសារការធ្វេសប្រហែសរបស់ខ្លួននោះ តើបុគ្គលដែលបានបើកបរបណ្តាលឱ្យអ្នកដទៃស្លាប់ដោយអចេតនានោះ ត្រូវទទួលខុសត្រូវព្រហ្មទណ្ឌដែរឬទេ? នៅក្នុងអត្ថបទនេះ យើងនឹងបង្ហាញពី៖ ១. ការទទួលខុសត្រូវព្រហ្មទណ្ឌជាលក្ខណៈទូទៅ ២. ការបើកបរបណ្តាលឱ្យអ្នកដទៃស្លាប់ដោយអចេតនា។

### ១. អំពីការទទួលខុសត្រូវព្រហ្មទណ្ឌជាលក្ខណៈទូទៅ

ជាគោលការណ៍ បុគ្គលម្នាក់ត្រូវទទួលខុសត្រូវព្រហ្មទណ្ឌ លុះត្រាតែអំពើនោះបំពេញនូវធាតុផ្សំនៃបទល្មើស រួមមានដូចជា៖ **ធាតុនីត្យានុកូល** (ច្បាប់ចែងថាអំពើនោះជាបទល្មើស) **ធាតុសត្យានុម័ត** (សកម្មភាពដែលបង្កឱ្យកើតមានបទល្មើស) និង**ធាតុអត្តនោម័ត** (ឆន្ទៈ ឬបំណងក្នុងការប្រព្រឹត្ត)។

នៅក្នុងករណីខាងលើ បុគ្គលនោះមិនមាន «ចេតនា» ក្នុងការធ្វើឱ្យមនុស្សស្លាប់នោះទេ ដែលវាហាក់ដូចជាខ្វះធាតុអត្តនោម័ត (បំណងសម្រាប់ធ្វើឱ្យបទល្មើសកើតឡើង) ដែលយើងអាចនឹងគិតថាបុគ្គលនោះអាចរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌ (ការផ្តន្ទាទោសដាក់ពន្ធនាគារ ឬ/និងពិន័យជាប្រាក់)។ ប៉ុន្តែ នៅក្នុងក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩ ("**ក្រមព្រហ្មទណ្ឌ**") និងច្បាប់ពិសេសផ្សេងទៀត បានចែងយ៉ាងច្បាស់ថា ចំពោះករណីដែលមានការធ្វេសប្រហែសនៅពេលបើកបរ ហើយបណ្តាលឱ្យមានមនុស្សស្លាប់ គឺមិនរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌឡើយ។

### ២. ការបើកបរបណ្តាលឱ្យអ្នកដទៃស្លាប់ដោយអចេតនា

យោងតាម **មាត្រា ៤ នៃក្រមព្រហ្មទណ្ឌ** បានចែងថា៖ *"ពុំមានបទល្មើសទេ ប្រសិនបើគ្មានចេតនាប្រព្រឹត្ត ប៉ុន្តែក្នុងករណីដែលច្បាប់បានចែងទុកមុន បទល្មើសមួយអាចកើតចេញពីការមិនប្រុងប្រយ័ត្ន ការខ្ជីខ្ជា ការធ្វេសប្រហែស ឬការមិនគោរពកាតព្វកិច្ចដោយឡែកណាមួយ"*។ មានន័យថា ចេតនាក្នុងប្រព្រឹត្តបទល្មើសគឺសំខាន់ បើគ្មានចេតនាធ្វើទេគឺមិនមានបទល្មើសទេ តែចំពោះអំពើដែលកើតចេញពីការធ្វេសប្រហែស ហើយត្រូវបានច្បាប់ចែងថាជាបទល្មើស នោះយើងមិនអាចរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌឡើយ។

ជាក់ស្តែង **មាត្រា ២០៧ នៃក្រមព្រហ្មទណ្ឌ** បានចែងថា៖

> *"បទមនុស្សឃាតដោយអចេតនា គឺជាអំពើបណ្តាលឱ្យស្លាប់អ្នកដទៃដោយ៖*
>
> *១. ការធ្វេសប្រហែស ការមិនប្រុងប្រយ័ត្ន ឬការខ្ជីខ្ជា។*



*__ការបដិសេធ:__ ព័ត៌មានដែលបានរៀបរៀងនៅក្នុងព្រឹត្តិបត្រគតិយុត្តរបស់អេណា គឺក្នុងគោលបំណងសម្រាប់ផ្តល់ជាព័ត៌មានតែប៉ុណ្ណោះ និងមិនផ្តោតសំខាន់ ទៅលើការប្រឹក្សាយោបល់ផ្នែកច្បាប់ឡើយ។ សូមធ្វើការកត់សម្គាល់ថា ការប្រឹក្សាផ្នែកច្បាប់ត្រូវធ្វើឡើង និងផ្តល់ជូនដោយមេធាវីប្រកបដោយសមត្ថភាព ព្រមទាំងគុណភាព ដែលធ្វើការប្រឹក្សាយោបល់ទៅលើគ្រប់ស្ថានភាពទាំងអស់។*

ANNA & ASSOCIATES
Law Office

*២. ការបំពានលើកាតព្វកិច្ចសន្តិសុខ ឬកាតព្វកិច្ចប្រុងប្រយ័ត្នដែលច្បាប់តម្រូវ។ បទមនុស្សឃាតដោយអចេតនា ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំ ទៅ ៣ (បី) ឆ្នាំ និងពិន័យជាប្រាក់ពី ២.០០០.០០០ (ពីរលាន) រៀល ទៅ ៦.០០០.០០០ (ប្រាំមួយលាន) រៀល។"*

ឧទាហរណ៍៖ បុគ្គល «ក» បានកាន់ដែកយ៉ាងធ្ងន់លើអគារ ហើយបានទម្លាក់ដែកនោះចុះមកក្រោមដោយមិនខ្វល់ពីមនុស្សនៅខាងក្រោម។ ដែកនោះបានធ្លាក់ត្រូវបុគ្គល «ខ» បណ្តាលឱ្យស្លាប់។ ក្នុងករណីនេះ បុគ្គល «ក» ត្រូវទទួលទោសដូចបានលើកឡើងខាងលើ ទោះបីជាសកម្មភាពរបស់បុគ្គល «ក» ធ្វើឡើងដោយគ្មានចេតនាសម្លាប់ក៏ដោយ។

ចំពោះករណីបើកបរបណ្តាលឱ្យអ្នកដទៃស្លាប់យោងតាម **មាត្រា ៨៥ នៃច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក ឆ្នាំ២០១៥** បានចែងថា៖ *"ជនណាបើកបរដោយធ្វេសប្រហែស ខ្ជីខ្ជា មិនប្រុងប្រយ័ត្ន ឬមិនគោរពកាតព្វកិច្ចដែលបទប្បញ្ញត្តិស្តីពីចរាចរណ៍ផ្លូវគោកតម្រូវបណ្តាលឱ្យអ្នកដទៃស្លាប់ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំ ទៅ ៣ (បី) ឆ្នាំ និងពិន័យជាប្រាក់ពី ៤ ០០០ ០០០ (បួនលាន) ទៅ ១៥ ០០០ ០០០ (ដប់ប្រាំលាន) រៀល [...]"*។

ការបើកបរបង្កឱ្យអ្នកដទៃស្លាប់ នឹងត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី **២ ឆ្នាំ ទៅ ៥ ឆ្នាំ** និងពិន័យជាប្រាក់ពី **១០ លានរៀល ទៅ ២៥ លានរៀល** ប្រសិនបើស្ថិតក្នុងស្ថានភាពណាមួយដូចខាងក្រោម៖

ក. បើកបរដោយគ្មានបណ្ណបើកបរ ឬមានបណ្ណបើកបរតែមិនត្រឹមត្រូវតាមប្រភេទយានយន្ត។

ខ. ស្ថិតក្នុងស្ថានភាពស្រវឹង (អត្រាជាតិអាកុលចាប់ពី ០,៤០ មីលីក្រាមក្នុងមួយលីត្រខ្យល់ ឬ ០,៨០ ក្រាមក្នុងមួយលីត្រឈាមឡើងទៅ)។

គ.បណ្តាលឱ្យមានមនុស្សស្លាប់ច្រើននាក់។

ឃ. រត់គេចខ្លួនពីកន្លែងកើតហេតុក្នុងគោលបំណងគេចវេះពីការទទួលខុសត្រូវ។

ដូច្នេះ ការបើកបរបណ្តាលឱ្យមនុស្សស្លាប់ច្រើននាក់ គឺជាស្ថានទម្ងន់ទោសដែលធ្វើឱ្យអ្នកបើកបរត្រូវទទួលទោសដាក់**ពន្ធនាគារពី ២(ពីរ)ឆ្នាំ ទៅ ៥(ប្រាំ) ឆ្នាំ** និងពិន័យជាប្រាក់ពី **១០(ដប់)លាន ទៅ ២៥ (ម្ភៃប្រាំ) លានរៀល**។

## សេចក្តីសន្និដ្ឋាន

សរុបជារួមមកការបើកបរបង្កឱ្យអ្នកដទៃស្លាប់ដោយអចេតនានេះ គឺមិនត្រូវរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌនោះទេ។ មិនតែប៉ុណ្ណោះអំពើមួយនេះមិនត្រឹមតែមានចែងនៅក្នុងក្រមព្រហ្មទណ្ឌនោះទេ សូម្បីតែច្បាប់ពិសេសដូចជា ច្បាប់ចរាចរណ៍ផ្លូវគោក ក៏បានចែងពីទោសបញ្ញត្តិសម្រាប់អំពើនៃបទល្មើសមួយនេះផងដែរ។


**ទំនាក់ទំនងមកកាន់៖**

**ការិយាល័យមេធាវី អេណា និងសហការី**

**គេហទំព័រ**: www.anna-associates.com

**អ៊ីម៉ែល**: info@anna-associates.com

**លេខទូរស័ព្ទ**: (+៨៥៥) ៩៩ ៨៨៨ ៧៣៧

**អាសយដ្ឋាន៖**

**អាសយដ្ឋានការិយាល័យ**: អាគារលេខ២២៣៤ ជាន់ទី៧ មហាវិថីម៉ៅសេទុង សង្កាត់ទំនប់ទឹក ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា




*__ការបដិសេធ__: ព័ត៌មានដែលបានរៀបរៀងនៅក្នុងព្រឹត្តិបត្រគតិយុត្តរបស់អេណា គឺក្នុងគោលបំណងសម្រាប់ផ្តល់ជាព័ត៌មានតែប៉ុណ្ណោះ និងមិនផ្តោតសំខាន់ ទៅលើការប្រឹក្សាយោបល់ផ្នែកច្បាប់ឡើយ។ សូមធ្វើការកត់សម្គាល់ថា ការប្រឹក្សាផ្នែកច្បាប់ត្រូវធ្វើឡើង និងផ្តល់ជូនដោយមេធាវីប្រកបដោយសមត្ថភាព ព្រមទាំងគុណភាព ដែលធ្វើការប្រឹក្សាយោបល់ទៅលើគ្រប់ស្ថានភាពទាំងអស់។*